# សេចក្តីប្រកាសព័ត៌មាន

## ការចាត់តាំងសហមេធាវីបរទេសរបស់លោក **នួន ជា**

នៅថ្ងៃនេះលោក **នួន ជា** បានជ្រើសរើសលោក Michiel Pestman ជនជាតិហូឡង់ ជាសហមេធាវីបរទេសធ្វើការជាមួយលោក **សុន អរុណ** សហមេធាវីកម្ពុជា ។

លោក Michiel Pestman គឺជាដៃគូនៅការិយាល័យមេធាវីឈ្មោះ Bohler Koppe Wijingaarden ដែលមានទីតាំងនៅទីក្រុងអាំស្ទែដាំ ។ លោក Pestman ជាសមាជិកនៃគណៈមេធាវីអាំស្ទែដាំចាប់តាំងពីឆ្នាំ ១៩៩៤មកម្ល៉េះ ។ គាត់ប្រកបវិជ្ជាជីវៈក្នុងវិស័យច្បាប់ព្រហ្មទណ្ឌនៅតុលាការជាតិនិងតុលាការអន្តរជាតិ។ ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០១ គាត់ជាសមាជិកក្រុមតំណាងឲ្យរដ្ឋាភិបាល Bosnia និង Herzegovinia នៅតុលាការយុត្តិធម៌អន្តរជាតិនៅក្នុងរឿងក្តីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងពួកស៊ែប(Serbia)។ ពីឆ្នាំ ២០០៣ គាត់ការពាររឿងក្តីរបស់លោក Moinina Fofana នៅចំពោះមុខតុលាការពិសេសសៀរ៉ាឡេអូន នៅក្នុងសវនាការប្រឆាំងមេដឹកនាំកងឈ្លបរដ្ឋាភិបាល ដែលត្រូវតុលាការផ្តន្ទាទោសកាលពីសប្តាហ៍មុនឲជាប់ក្នុងពន្ធនាគាររយៈពេល៦ឆ្នាំពីបទឧក្រិដ្ឋកម្មសង្គ្រាម ។ ចំណែកឯនៅក្នុងតុលាការជាតិវិញ គាត់បានការពាររឿងក្តីជាច្រើនដែលពាក់ព័ន្ធជាមួយជនជាប់ចោទពីបទភេរវកម្មនិងបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរដទៃទៀតនៅទ្វីបអឺរ៉ុបនិងទីកន្លែងផ្សេងៗទៀត ។ លោក Michiel Pestman បង្រៀនច្បាប់អន្តរជាតិនៅសកលវិទ្យាល័យអាំស្ទែដាំ ។

លោក Pestman និយាយថា"ខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយលោកមេធាវី **សុន អរុណ** និងសមាជិកនៃក្រុមការពារក្តីរបស់លោក **នួន ជា** ដទៃទៀត ។ ខ្ញុំនឹងធ្វើអ្វីគ្រប់បែបយ៉ាងដែលអាចធ្វើបាន ដើម្បីធានាថាកូនក្តីរបស់យើងទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ។ វាមានសារៈសំខាន់ណាស់ដែលលោក **នួន ជា** ទទួលបានការការពារដ៏ត្រឹមត្រូវ” ។

ពាក្យសុំចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារបស់គាត់បានបញ្ជូនទៅគណៈមេធាវីនៅថ្ងៃនេះ ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ២០០៧